# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Aug-2015, 10:14
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញាអន្តរជាតិ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៥

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ការជូនដំណឹងអំពីនីតិវិធីថ្មីសម្រាប់ដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពីសំណុំរឿង០០៣ និង០០៤ ទៅសំណុំរឿង០០២/០២

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ចម្លងជូន៖ |
|---|---|---|
| **សហព្រះរាជអាជ្ញា៖** | **អង្គជំនុំជម្រះសាលាដំបូង៖** | **ជនជាប់ចោទ៖** |
| Nicholas KOUMJIAN | ចៅក្រម **និល ណុន** ជាប្រធាន | នួន ជា |
| | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |
| ចម្លងជូន៖ | ចៅក្រម **យ៉ា សុខន** | **មេធាវីការពារក្តី៖** |
| ជា លាង | ចៅក្រម Claudia FENZ | សុន អរុណ |
| | ចៅក្រម **យូរ ឧត្តរា** | Victor KOPPE |

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

**មេធាវីប្រចាំការ៖**

ទូច វរល័ក្ស

Calvin SAUNDERS

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Mark B. HARMON

# សេចក្តីជូនដំណឹង

1. ដើម្បីកាត់បន្ថយការពន្យារពេលនៃការជំនុំជម្រះសំណុំរឿង០០២ឱ្យបានច្រើនបំផុត និងជាការឆ្លើយតបចំពោះការព្រួយបារម្ភ និងការចង់បាននាពេលថ្មីៗនេះរបស់មេធាវីការពារក្តី ទាក់ទងនឹងការដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនពីសំណុំរឿង០០៣ និង០០៤ ទៅក្នុងសំណុំរឿង០០២/០២ សហព្រះរាជអាជ្ញាអន្តរជាតិបានកែប្រែនីតិវិធីដែលត្រូវអនុវត្តតាមសម្រាប់ការដាក់បង្ហាញប្រភេទឯកសារទាំងនេះ។

2. នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ សហព្រះរាជអាជ្ញាបានដាក់សំណើមួយទៅអង្គជំនុំជម្រះសាលាដំបូងសុំបង្ហាញកំណត់ហេតុស្តាប់ចម្លើយ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលយកនៅក្នុងសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០២ ដោយស្នើឱ្យដាក់ឯកសារទាំងនេះទៅក្នុងសំណុំរឿង០០២[1]។ ឯកសារទាំងនេះរួមមាន ការសម្ភាសន៍ចំនួន ៥ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤៧ ដែលពាក់ព័ន្ធនឹងទំនប់ត្រពាំងថ្ម។ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងទៅភាគីឱ្យដាក់ការសង្កេតរបស់ខ្លួនអំពីផលប៉ះពាល់នៃការដាក់បង្ហាញនេះ។

3. ជាការឆ្លើយតប ទាំងមេធាវីការពារក្តី នួន ជា និង ខៀវ សំផន បានលើកឡើងថា ពួកគាត់មិនចង់ពិនិត្យមើលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថ្មីៗពីសំណុំរឿង០០៣ និង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០២ទេ ជាពិសេសប្រសិនបើសហព្រះរាជអាជ្ញាមិនដាក់ឯកសារទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះ ហើយស្នើសុំឱ្យទទួលយកឯកសារទាំងនេះ អនុលោមតាមវិធាន៨៧(៣) និង(៤) នៃវិធានផ្ទៃក្នុងទេនោះ[2]។

---

[1] ឯកសារ **E319/25** ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវឯកសារពីសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ អនុលោមតាមសំណុំរឿង០០៤-D193/28 ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥។

[2] **ប្រតិចារឹកសវនាការ (អង់គ្លេស) ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ មេធាវីការពារក្តី នួន ជា ទំព័រ ១៨ ម៉ោង 09.44.59** ["ខ្ញុំគិតថា វាដល់ពេលមួយដែលយើងគួរតែនិយាយថា វាល្មមគ្រប់គ្រាន់ហើយ។ សូមដាក់ពាក្យសុំទាំងនេះនៅកន្លែងដើមចុះ ក្នុងសំណុំរឿង០០៣ និង ០០៤ ។ ទុកឱ្យពួកគេដោះស្រាយទៅ"]។ **ប្រតិចារឹកសវនាការ (អង់គ្លេស) ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ មេធាវីការពារក្តី ខៀវ សំផន**

4. ដូចដែលសហព្រះរាជអាជ្ញាបានជូនដំណឹងនៅក្នុងសវនាការកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ តាមការរំពឹងទុក មានតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតិចតួចប៉ុណ្ណោះពីសំណុំរឿង០០៣ និង ០០៤ ដែលនឹងត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដោយសហព្រះរាជអាជ្ញា ឬភាគីដទៃទៀត។ ដូច្នេះ ការដាក់បង្ហាញឯកសារទាំងនេះមានគោលបំណងសំខាន់ដើម្បីធានាថា កាតព្វកិច្ចក្នុងការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាត្រូវបានអនុវត្ត ហើយអង្គជំនុំជម្រះ និងភាគី មានលទ្ធភាពចូលមើលឯកសារពីសំណុំរឿង០០៣ និង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០២ ប្រសិនបើ ពួកគាត់ចង់ពិនិត្យ និងប្រើប្រាស់ឯកសារទាំងនេះ។

5. មកទល់ពេលនេះ សហព្រះរាជអាជ្ញាដឹងថា មានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ១៧២០ ដែលត្រូវបានជូនដំណឹងនៅក្នុងសំណុំរឿង០០៤ ហើយមានពាក្យសុំចំនួន ៤៨៧ ដែលត្រូវបានដាក់នៅក្នុងសំណុំរឿង០០៣។ ការពិនិត្យទៅលើពាក្យសុំទាំងនេះដើម្បីកំណត់ចំណុចដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ គឺជាដំណើរការមួយដែលត្រូវចំណាយពេលច្រើន នៅខណៈពេលដែលសហព្រះរាជអាជ្ញាមានធនធានតិចតួច។ ការដាក់បង្ហាញនាពេលថ្មីៗនេះធ្វើឡើងបន្ទាប់ពីសហព្រះរាជអាជ្ញាពិនិត្យមើលលើកដំបូងចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានការបកប្រែចប់សព្វគ្រប់ជាភាសាអង់គ្លេស។ បច្ចុប្បន្ន សហព្រះរាជអាជ្ញាកំពុងពិនិត្យមើលពាក្យសុំដែលមានតែជាភាសាខ្មែរ ប៉ុន្តែ មានសេចក្តីសង្ខេបពីផ្នែកគាំពារជនរងគ្រោះ។

6. ដោយសារតែការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤ ជាន់គ្នាជាមួយនឹងសំណុំរឿង០០២/០២ ពាក្យសុំជាច្រើនប្រហែលជានឹងមានព័ត៌មានខ្លះដែលពាក់ព័ន្ធនឹងយ៉ាងហោចណាស់ផ្នែកមួយនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០២។ ជាឧទាហរណ៍ ក្នុងចំណោមឯកសារក្រុមទីពីរដែលបច្ចុប្បន្នកំពុងត្រូវបានពិនិត្យ សហព្រះរាជអាជ្ញាបានរកឃើញពាក្យសុំជាង ២០០ បន្ថែមទៀត ដែលមានព័ត៌មានខ្លះ ឬការលើកឡើងអំពីទំនប់ត្រពាំងថ្ម។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលរំពឹងថាពាក់ព័ន្ធនឹងផ្នែកផ្សេងៗទៀតនៃសំណុំរឿង០០២/០២ ដូចជា ការប្រព្រឹត្តិទៅលើជនជាតិចាម និងវៀតណាម នឹងមានចំនួនតិចជាង ប៉ុន្តែនៅតែច្រើនដដែល។

---

**ទំព័រ២៣ ម៉ោង** 09.52.32 ["បើសិនបើមិនសំខាន់ទេ សូមដកវាចេញចុះ ប្រសិនបើព្រះរាជអាជ្ញាចង់ប្រើពាក្យសុំទាំងនេះ នៅពេលនេះ ឬពេលក្រោយទៀត តាមរយៈការស្នើដាក់ឯកសារទាំងនេះ សូមទុកពេលវេលាឲ្យមេធាវីការពារក្តីមានពេលវិភាគឯកសារទាំងអស់"]។

7. ដូចទៅនឹងក្រុមទីមួយនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៃទំនប់ត្រពាំងថ្ម ដែលត្រូវបានដាក់បង្ហាញទៅក្នុងសំណុំរឿង០០២/០២ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ ដោយយកចេញពីសំណុំរឿង០០៤ សហព្រះរាជអាជ្ញាអន្តរជាតិរំពឹងថា នឹងមានការដាក់ឯកសារដែលបានកម្រិតនៃឯកសារទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះ ឧទាហរណ៍ ពាក្យសុំដែលមកពី ឬទាក់ទងផ្ទាល់ជាមួយនឹងសាក្សីដែលផ្តល់សក្ខីកម្ម ដើមបណ្តឹងរដ្ឋប្បវេណី ឬការចោទប្រកាន់សំខាន់ៗនៅក្នុងសវនាការ។ យ៉ាងណាក៏ដោយ ការដាក់បង្ហាញឯកសារសំខាន់បែបនេះទាំងអស់ នៅតែមានសារៈសំខាន់ ដើម្បីឲ្យភាគីទាំងអស់អាចចូលមើលឯកសារទាំងនេះ។

8. ដូច្នេះ ជាការឆ្លើយតបទៅនឹងការព្រួយបារម្ភរបស់មេធាវីការពារក្តីដែលបានលើកឡើងនៅសវនាការកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ និងជាការផ្តល់ជម្រើសឲ្យមេធាវីការពារក្តី ក្នុងការរួចផុតពីបន្ទុកការងារនៃការពិនិត្យទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ពីសំណុំរឿង០០៣ និង០០៤ ដែលសហព្រះរាជអាជ្ញាមិនមានបំណងដាក់ធ្វើជាភស្តុតាងនោះ សហព្រះរាជអាជ្ញាអន្តរជាតិនឹងដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពីសំណុំរឿង០០៣ និង០០៤ តាមវិធីខាងក្រោមនេះ។

9. នៅក្នុងការដាក់បង្ហាញនេះ សហព្រះរាជាអាជ្ញាអន្តរជាតិនឹងផ្តល់ឧបសម្ព័ន្ធមួយដែលរៀបរាប់អំពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពីសំណុំរឿង០០៣ និង០០៤ ដែលត្រូវបានរំពឹងថាដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងអំឡុងពេលសវនាការជំនុំជម្រះសំណុំរឿង០០២/០២ ដូចជា ពាក្យសុំដែលមកពី ឬទាក់ទងនឹងសាក្សីសំណុំរឿង០០២/០២, និងពួកដែលមានយ៉ាងជាក់លាក់នូវព័ត៌មានដែលមានតម្លៃជាភស្តុតាង ឬជាព័ត៌មានពិសេសស្តីពីបញ្ហាគន្លឹះនានានៃសវនាការ។ ពាក្យសុំផ្សេងទៀតដែលនៅសល់ដែលសហព្រះរាជអាជ្ញាមិនរំពឹងថាត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ នឹងត្រូវរៀបរាប់នៅក្នុងឧបសម្ព័ន្ធដោយឡែកមួយ។

10. នីតិវិធីដែលត្រូវបានកែប្រែថ្មីនេះត្រូវបានរំពឹងថានឹងកែសម្រួលដំណើរការដាក់បង្ហាញ អនុញ្ញាតឲ្យភាគីផ្តោតទៅលើឯកសារដែលភាគច្រើននឹងត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងត្រូវបានប្រើប្រាស់នៅក្នុងអំឡុងពេលសវនាការជំនុំជម្រះសំណុំរឿង០០២/០២ ប៉ុន្តែនៅពេលជាមួយគ្នានោះដែរ ត្រូវធានាថា

ឯកសារដែលពាក់ព័ន្ធទាំងអស់ពីសំណុំរឿង០០៣ និង០០៤ ត្រូវបានដាក់បង្ហាញ និងឲ្យភាគីទាំងអស់អាចចូលមើលបាន។

11. សហព្រះរាជអាជ្ញាអន្តរជាតិនឹងអនុវត្តតាមនីតិវិធីថ្មីនេះ ដោយចាប់ផ្តើមពីក្រុមបន្ទាប់នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៃទំនប់ត្រពាំងថ្មក្នុងសំណុំរឿង០០៤ ដែលនឹងត្រូវដាក់បង្ហាញក្នុងពេលឆាប់ៗខាងមុខ បន្ទាប់ពីមានការអនុញ្ញាតរបស់ កសចស។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៥ | Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | រាជធានីភ្នំពេញ | |